# បដិមាស្វាប្រយុទ្ធគ្នាមកពីប្រាសាទចិន (កោះកេរ)

បដិមាស្វាមាឌធំចំនួនពីរឈរប្រយុទ្ធគ្នាដែលឆ្លាក់លើជើងទម្រតែមួយ បច្ចុប្បន្នកំពុងតាំងបង្ហាញនៅសារមន្ទីរជាតិភ្នំពេញ។ បដិមានេះឆ្លាក់ពីថ្មភក់ដែលមានកម្ពស់ ២,៧៨ម៉ែត្រ និងចុះបញ្ជីលេខ ក.១៦៦៤ ដោយសារមន្ទីរជាតិភ្នំពេញ។ បដិមានេះរកឃើញនៅប្រាសាទចិន នៃតំបន់ប្រាសាទកោះកេរ ក្នុងរវាងទសវត្សរ៍១៩៦០ ដោយក្រុមអ្នកស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ាប្រទេស។ រូបភាពស្វាប្រយុទ្ធគ្នាឆ្លាក់ចេញជាបដិមាធ្វើអំពីថ្មបែបនេះ មានលក្ខណៈកម្របំផុតនៅក្នុងសិល្បៈខ្មែរ ដ្បិតកន្លងមកយើងធ្លាប់តែឃើញជាចម្លាក់នៅលើថ្មតាមជញ្ជាំងប្រាសាទតែប៉ុណ្ណោះ។ តើបដិមាស្វាប្រយុទ្ធគ្នាមកពីប្រាសាទចិន (កោះកេរ) មានលក្ខណៈបែបណាខ្លះ?

កន្លងមក អ្នកស្រាវជ្រាវជាច្រើនបានឯកភាពគ្នាកំណត់អត្តសញ្ញាណរូបបដិមាស្វាប្រយុទ្ធគ្នានេះថា ជាតួអង្គស្វាត្រូវជាបងប្អូនបង្កើតនឹងគ្នានៅក្នុងទេវកថាហិណ្ឌូរបស់ឥណ្ឌាដ៏ល្បីល្បាញគឺរឿងរាមាយណ ឬខ្មែរហៅថា «រាមកេរ្តិ៍»។ តួអង្គទាំងពីរនេះ គឺជា ពាលី (Valin) និងសុគ្រីព (Sugriva)។ ត្រង់ឈុតនេះ សាច់រឿងដំណាលតាមគម្ពីរ កិស្កិន្ធកន្ទ (Kishkindhakanda) ក្បាលទី៤ ជំពូកទី៩ ថា៖ «ពាលី និងសុគ្រីពដែលជាបងប្អូននឹងគ្នា មានជម្លោះដណ្តើមរាជ្យបល្ល័ង្កពីគ្នាទៅវិញទៅមក។ ពាលីដែលជាបង គេចាត់ទុកជាតួអង្គមានភាពមិនស្មោះត្រង់ដែលតែងប៉ងប្រាថ្នាដណ្តើមរាជ្យបល្ល័ង្កស្របច្បាប់ពីសុគ្រីបដែលជាប្អូនរបស់ខ្លួន។ សុគ្រីព ដឹងខ្លួនថា ខ្លួនមិនមានសមត្ថភាពប្រយុទ្ធឈ្នះពាលីដែលជាបង ក៏ទៅពឹងពាក់ព្រះរាមដែលជាអវតាររបស់ព្រះនារាយណ៍។ ព្រះរាមបានសន្យាជាមួយសុគ្រីពថានឹងជួយសម្លាប់ពាលី ដាច់ថ្លៃជាមួយសុគ្រីពជួយតាមស្វែងរកមហេសីរបស់ទ្រង់គឺព្រះនាងសីតាដែលត្រូវក្រុងរាពណ៍ចាប់យកទៅ។ ការប្រយុទ្ធគ្នាលើកដំបូងសុគ្រីពមានរបួសធ្ងន់ធ្ងរណាស់ ដោយប្រយុទ្ធមិនឈ្នះពាលីឡើយ ដោយហេតុថាព្រះរាមមិនបានទៅជួយតាមការសន្យា។ ដោយក្តីខឹងសម្បារនឹងព្រះរាមក្បត់សន្យា សុគ្រីពបានរត់ទៅជួបព្រះរាមនៅលើកំពូលភ្នំ ហើយព្រះរាមក៏បកស្រាយថា ទ្រង់ពុំអាចសម្គាល់បានរវាងតួអង្គស្វាទាំងពីរនាក់បងប្អូនណាស់ ដោយសារតែរូបរាងដូចគ្នា។ ក្រោយមក ទើបព្រះរាមបង្គាប់ឱ្យសុគ្រីពទៅប្រយុទ្ធជាមួយពាលីម្តងទៀតដោយពាក់កម្រងផ្កា ដើម្បីងាយស្រួលទ្រង់ចំណាំបាន។ នៅពេលប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញរវាងបងប្អូនទាំងពីរ ព្រះរាមបានពួននៅក្រោយដើមឈើមួយ ហើយនៅពេលដែលទ្រង់ឃើញសុគ្រីពចុះខ្សោយកម្លាំងខ្លាំង ទ្រង់ក៏ផ្លែងសរទៅលើពាលីត្រូវចំពីក្រោយស្លាប់។»

ជាទូទៅនៅក្នុងសិល្បៈខ្មែរ គេចាប់ផ្តើមឃើញមានចម្លាក់ពាលីនិងសុគ្រីពប្រយុទ្ធគ្នាចាប់ពី ស.វ.ទី១០មក ហើយភាគច្រើនគេឆ្លាក់នៅលើផ្តែរ ហោជាង ជញ្ជាំង ។ល។ ជាក់ស្តែង ដូចជានៅ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ប្រាសាទបន្ទាយស្រី និងប្រាសាទអង្គរវត្តជាដើម។ ដោយឡែក ប្រសិនជាបដិមាវិញ គឺមានតែនៅប្រាសាទចិន (តំបន់កោះកេរ) ដែលយើងកំពុងលើកមកសិក្សាតែមួយនេះប៉ុណ្ណោះ។ តួអង្គទាំងពីរនេះ សិល្បករខ្មែរបុរាណឆ្លាក់ចេញមកមានរូបរាងដូចគ្នាបេះបិទតែម្តង ហើយការស្លៀកពាក់ និងគ្រឿងតុបតែងលម្អទៀតសោតក៏មានលក្ខណៈដូចគ្នាដែរ។ បដិមាទាំងពីរពាក់មកុដរាងដូចផ្នួងសក់ (ជដាមកុដ) ពាក់គ្រឿងអលង្ការជាច្រើននៅលើរាងកាយ និងស្លៀកសំពត់ចងក្បិនដែលមានផ្កាក់ជាយធំសំយ៉ាកលើភ្លៅទាំងពីរខាងមុខដូចបដិមាដទៃទៀតនៅក្នុងរចនាបថកោះកេរ នាស.វ.ទី១០ដែរ។ អ្វីដែលយើងគួរកត់សម្គាល់នោះគឺ ថ្មដែលគេយកមកឆ្លាក់មានតែមួយដុំប៉ុណ្ណោះ ដោយភ្ជាប់គ្នាតាំងពីជើងទម្ររហូតដល់រូបដំហរបដិមាតែម្តង។ ដំហររបស់បដិមា គឺដាក់ជើងញែកចេញពីគ្នា ដោយជុចជង្គង់ ពើងទ្រូងដាក់គ្នា ក្នុងកាយវិការប្រយុទ្ធដ៏ម៉ឺងម៉ាត់។ រីឯដៃបដិមាទាំងពីរដាក់ដូចគ្នា គឺម្ខាងដាក់នៅលើស្វាដៃគូប្រយុទ្ធ និងម្ខាងទៀតក្តាប់នៅខាងក្រោយភ្លៅ។

អ្វីដែលគួរលើកយកមកពិចារណានោះគឺ តើហេតុអ្វីបានជាសិល្បករឆ្លាក់បដិមានេះតម្កល់នៅប្រាសាទចិន?

គេពុំដឹងច្បាស់អំពីទីតាំងតម្កល់បដិមានេះទេ បើទោះបីបដិមាផ្សេងទៀតគេដឹងអំពីទីតាំងតម្កល់ជាក់លាក់ក៏ដោយ ឧទាហរណ៍ បដិមាបង្ហាញអំពីសង្គ្រាមគុរុក្សេត្រនៃរឿងមហាភារតតម្កល់នៅប្រាង្គគោបុរខាងលិច និងបដិមាហនុមាននៃរឿងរាមាយណតម្កល់នៅប្រាង្គគោបុរខាងកើត។ ប៉ុន្តែ យើងអាចសាកល្បងគិតថា សិល្បករនៅក្នុងតំបន់កោះកេរ នាស.វ.ទី១០ និយមឆ្លាក់រូបបដិមាធំៗខ្លាំងណាស់ ដូច្នេះហើយ បើសិនជាតួអង្គហនុមាននៃរឿងរាមាយណ និងតួអង្គផ្សេងៗនៅក្នុងរឿងមហាភារត បានឆ្លាក់ជាបដិមាតម្កល់នៅប្រាសាទចិនដែរ វាហាក់ដូចពុំមានអ្វីប្លែកចំពោះបដិមាពាលីនិងសុគ្រីពប្រយុទ្ធគ្នាទេ ពោល គឺទំនងជាការវិវត្តថ្មីមួយនៃសិល្បៈក្នុងតំបន់ដោយការច្នៃប្រឌិតឆ្លាក់តួអង្គ នៃរឿងទេវកថាឱ្យចេញជាបដិមាយកទៅតម្កល់ក្នុងប្រាសាទតែម្តង។ ដូច្នេះ បើគិតទៅមិនសូវខុសគ្នាប៉ុន្មានអំពីការឆ្លាក់សាច់រឿងទេវកថាជាចម្លាក់នៅតាមផ្តែរ ហោជាង ឬជញ្ជាំងប្រាសាទនោះទេ។

ជារួមមក បដិមាស្វាប្រយុទ្ធគ្នាមកពីប្រាសាទចិន គឺជាស្នាដៃច្នៃប្រឌិតថ្មីមួយបែបរបស់សិល្បករបុរាណខ្មែរ ដែលបានយកសាច់រឿងទេវកថារាមយណ ត្រង់ឈុតពាលី និងសុគ្រីពប្រយុទ្ធគ្នាឆ្លាក់ឱ្យចេញជាបដិមា។ ចម្លាក់បដិមានេះ មើលទៅមានលក្ខណៈរាងកាយមាំមួន និងមានភាពរស់រវើកយ៉ាងខ្លាំងដូចទៅនឹងធម្មជាតិពិតៗ។ ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញពីភាពប៉ិនប្រសប់របស់បុព្វបុរសខ្មែរទៅលើការងារសិល្បៈផ្នែកសាសនា៕

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

## ឯកសារយោង


**Chen Chanrathana**

2011. *Le site de Koh Ker et le regne de Jayavarman IV, Histoire, art et archéologie*, Thèse de doctorat d’Archéologie et Histoire de l’art de l’Asie du Sud et du Sud-Est, Universite Sorbonne Nouvelle – Paris 3.

**Jessup, H.I.**

2006. *Masterpieces of the National Museum of Cambodia,* Friend of Khmer Culture, Inc. USA.

**Roveda, V.**

2005. *Image of the god,* River Book, Bangkok.




រូបលេខ១៖ បដិមាពាលីនិងសុគ្រីព ដាក់តាំងនៅសារមន្ទីរជាតិភ្នំពេញ ឆ្នាំ២០២២

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២២៖ បដិមាពាលីនិងសុគ្រីព ដាក់តាំងនៅសារមន្ទីរជាតិកម្ពុជា ឆ្នាំ២០២២



រូបលេខ២៣៖ បដិមាពាលីនិងសុគ្រីព ដាក់តាំងនៅសារមន្ទីរជាតិភ្នំពេញ ឆ្នាំ២០២២

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៨៖ បដិមាពាលីនិងសុគ្រីព ថតនៅឆ្នាំ១៩៦៤ (ប្រភព EFEO)



រូបលេខ២៩៖ បដិមាពាលីនិងសុគ្រីព ថតនៅឆ្នាំ១៩៦៤ (ប្រភព EFEO)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៦៖ បដិមាពាលីនិងសុគ្រីព ថតនៅឆ្នាំ១៩៦៤ (ប្រភព EFEO)



រូបលេខ៧៖ បដិមាពាលីនិងសុគ្រីព នៅទីតាំងដើម (ប្រភព EFEO)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី